ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

MINISTRY OF POST AND TELECOMMUNICATIONS

# សៀវភៅមគ្គុទ្ទេសក៍

## ស្តីពី

## មុខងារពិនិត្យស្ថានភាពលេខអាយមុី
## នៃប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍
## ទូរគមនាគមន៍ប្រើស៊ីម (ប្រព័ន្ធ EIRS)



ខែកក្កដា ឆ្នាំ២០២៦

## មាតិកា


១. សេចក្តីផ្តើម ........................................................ ១

២. លេខអាយម៉ីនៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ........................................................ ១

២.១. តើអ្វីទៅជាលេខអាយម៉ី? ........................................................ ១

២.២. របៀបស្វែងរកលេខអាយម៉ី ........................................................ ១

៣. ស្ថានភាពលេខអាយម៉ី ........................................................ ១

៣.១. ហេតុអ្វីត្រូវពិនិត្យស្ថានភាពលេខអាយម៉ី? ........................................................ ១

៣.២. ព័ត៌មាននៃការពិនិត្យស្ថានភាពលេខអាយម៉ី ........................................................ ១

៤. មុខងារពិនិត្យស្ថានភាពលេខអាយម៉ី........................................................ ២

៤.១. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈវេបសាយ ........................................................ ២

៤.២. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈកម្មវិធីទូរសព្ទចល័ត ........................................................ ៣

៤.៣. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈសេវាយូ.អេស.អេស.ឌី (USSD) ........................................................ ៥

៤.៤. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈសេវាសារខ្លី (SMS)........................................................ ៦

## តារាងកំណែ

| ល.រ | កាលបរិច្ឆេទ | ជំនាន់ | បរិយាយ |
|---|---|---|---|
| ០១ | ០១ កក្កដា ២០២៦ | ១.០ | ជំនាន់ដំបូង |

## ១. សេចក្ដីផ្ដើម

សៀវភៅមគ្គុទ្ទេសក៍ស្ដីពីមុខងារពិនិត្យស្ថានភាពលេខអាយម៉ី នៃប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម (ប្រព័ន្ធ EIRS) ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្ដល់ព័ត៌មានពីរបៀបពិនិត្យនិងផ្ទៀងផ្ទាត់លេខអាយម៉ីនៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

## ២. លេខអាយម៉ីនៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

### ២.១. តើអ្វីទៅជាលេខអាយម៉ី?

លេខអាយម៉ី (IMEI - International Mobile Equipment Identity) គឺជាលេខអត្តសញ្ញាណអន្តរជាតិសម្រាប់សម្គាល់ទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលមានចំនួន ១៥ខ្ទង់។ ទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនីមួយៗ មានលេខអាយម៉ីមិនដូចគ្នាឡើយ។

**សម្គាល់៖** លេខអាយម៉ីមិនពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ឡើយ។

### ២.២. របៀបស្វែងរកលេខអាយម៉ី

លេខអាយម៉ី អាចត្រូវបានស្វែងរកតាមវិធីដូចខាងក្រោម៖

- ចុច ***#06#** នៅលើផ្ទាំងលេខ នៃទូរសព្ទចល័តរបស់អ្នក
- នៅក្នុងមុខងារ**ការកំណត់** (Settings) នៃទូរសព្ទចល័តរបស់អ្នក
- នៅលើ**ប្រអប់ដើម** (Original Box) របស់ទូរសព្ទចល័ត។

## ៣. ស្ថានភាពលេខអាយម៉ី

### ៣.១. ហេតុអ្វីត្រូវពិនិត្យស្ថានភាពលេខអាយម៉ី?

ការពិនិត្យស្ថានភាពលេខអាយម៉ីជាមួយប្រព័ន្ធ EIRS គឺដើម្បីដឹងថាលេខអាយម៉ីនោះជាលេខត្រឹមត្រូវឬមិនត្រឹមត្រូវ និងបានដំណើរការឬមិនទាន់បានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជា។

### ៣.២. ព័ត៌មាននៃការពិនិត្យស្ថានភាពលេខអាយម៉ី

ស្ថានភាពលេខអាយម៉ីអាចមានលទ្ធផល ១ក្នុងចំណោមលទ្ធផល ៤ដូចខាងក្រោម៖

- **លេខអាយម៉ីត្រឹមត្រូវ និងបានដំណើរការ៖** មានន័យថា លេខអាយម៉ីនេះត្រឹមត្រូវ និងបានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជាជាធម្មតា។
- **លេខអាយម៉ីត្រឹមត្រូវ និងមិនទាន់បានដំណើរការ៖** មានន័យថា លេខអាយម៉ីនេះត្រឹមត្រូវ និងមិនទាន់បានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជានៅឡើយ។ ស្ថានភាពនេះនឹងផ្លាស់ប្ដូរមក "លេខអាយម៉ីត្រឹមត្រូវ និងបានដំណើរការ" ក្នុងអំឡុងពេល ៧២ម៉ោង បន្ទាប់ពីឧបករណ៍ត្រូវបានប្រើប្រាស់ជាមួយស៊ីមកាតឬអ៊ីស៊ីមជាលើកដំបូង។
- **លេខអាយម៉ីមិនត្រឹមត្រូវ និងបានដំណើរការ៖** មានន័យថា លេខអាយម៉ីនេះមិនត្រឹមត្រូវ និងបានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជាជាធម្មតា។
- **លេខអាយម៉ីមិនត្រឹមត្រូវ និងមិនទាន់បានដំណើរការ៖** មានន័យថា លេខអាយម៉ីនេះមិនត្រឹមត្រូវ និងមិនទាន់បានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជានៅឡើយ។ ស្ថានភាពនេះនឹង

ផ្លាស់ប្តូរមក "លេខអាយម៉ីមិនត្រឹមត្រូវ និងបានដំណើរការ" ក្នុងអំឡុងពេល ៧២ម៉ោង បន្ទាប់ពីឧបករណ៍ត្រូវបានប្រើប្រាស់ជាមួយស៊ីមកាតឬអ៊ីស៊ីមជាលើកដំបូង។

**សម្គាល់៖** សូមជៀសវាងទិញទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមទាំងឡាយណា ដែលមានលេខអាយម៉ីមិនត្រឹមត្រូវមកប្រើប្រាស់។

## ៤. មុខងារពិនិត្យស្ថានភាពលេខអាយម៉ី

ស្ថានភាពលេខអាយម៉ី អាចត្រូវបានពិនិត្យតាមរយៈប្រព័ន្ធ EIRS ដោយឥតគិតថ្លៃ តាមរបៀបណាមួយដូចខាងក្រោម៖

- វេបសាយ: **www.eirs.gov.kh**
- កម្មវិធីទូរសព្ទចល័តៈ ទាញយកកម្មវិធី “**IMEI KH**” ពី App Store, Play Store ឬ AppGallery
- សេវាយូ.អេស.អេស.ឌី (USSD): ចុច ***1205#** រួចចុចបញ្ជូន និងអនុវត្តតាមការណែនាំ
- សេវាសារខ្លី (SMS): វាយ **CHK**<ដកឃ្លា><**លេខអាយម៉ី១៥ខ្ទង់**> រួចចុចបញ្ជូនទៅលេខ **1205**។

### ៤.១. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈវេបសាយ

អ្នកប្រើប្រាស់អាចពិនិត្យស្ថានភាពលេខអាយម៉ីនៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម តាមរយៈវេបសាយនៃប្រព័ន្ធ EIRS ដូចខាងក្រោម៖

១. ចូលទៅវេបសាយ **www.eirs.gov.kh** ឬស្កេន QR Code ដូចខាងក្រោម

www.eirs.gov.kh

២. បញ្ចូលលេខអាយម៉ីចំនួន ១៥ខ្ទង់ (ជាលេខឡាតាំង) នៅក្នុងប្រអប់ “**សូមបញ្ចូលលេខអាយម៉ីចំនួន ១៥ខ្ទង់**” រួចចុចប៊ូតុង **ពិនិត្យស្ថានភាពលេខអាយម៉ី**



៣. ចុចសញ្ញាធីកក្នុងប្រអប់ I'm not a robot រួចចុចប៊ូតុង ពិនិត្យស្ថានភាពលេខអាយម៉ី







៤. លទ្ធផលស្ថានភាពលេខអាយម៉ីនឹងបង្ហាញ ១ក្នុងចំណោម ៤ប្រភេទ ដូចខាងក្រោម៖













## ៤.២. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈកម្មវិធីទូរសព្ទចល័ត

អ្នកប្រើប្រាស់អាចពិនិត្យស្ថានភាពលេខអាយម៉ី នៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម តាមរយៈកម្មវិធីទូរសព្ទចល័ត IMEI KH ដូចខាងក្រោម៖

១. ទាញយកកម្មវិធីទូរសព្ទចល័ត IMEI KH ពី App Store, Play Store ឬ AppGallery ឬតាមរយៈ QR Code ដូចខាងក្រោម




IMEI KH Mobile App

២. បញ្ចូលលេខអាយម៉ីចំនួន ១៥ខ្ទង់ (ជាលេខឡាតាំង) នៅក្នុងប្រអប់ “**សូមបញ្ចូលលេខអាយម៉ីចំនួន ១៥ខ្ទង់**” រួចចុចប៊ូតុង **ពិនិត្យស្ថានភាពលេខអាយម៉ី**




ម្យ៉ាងទៀត អាចស្កេនបារកូដ ឬចុចលើ “**ស្កេនបារកូដ**” (ដូចរូប)។



៣. លទ្ធផលស្ថានភាពលេខអាយម៉ីនឹងបង្ហាញ ១ក្នុងចំណោម ៤ប្រភេទដូចខាងក្រោម៖



## ៤.៣. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈសេវាយូ.អេស. អេស.ឌី (USSD)

អ្នកប្រើប្រាស់អាចពិនិត្យស្ថានភាពលេខអាយម៉ី នៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមតាមរយៈសេវាយូ.អេស.អេស.ឌី (USSD) ដូចខាងក្រោម

១. ចុច *1205# រួចចុចបញ្ជូន

២. វាយលេខ 1 (លេខឡាតាំង) រួចចុចពាក្យ “Send” ឬ “Reply”

៣. វាយលេខអាយម៉ីចំនួន ១៥ខ្ទង់ (លេខឡាតាំង) រួចចុចពាក្យ “Send” ឬ “Reply” ដើម្បីទទួលបានព័ត៌មានពីស្ថានភាពលេខអាយម៉ី។ បន្ទាប់មក អ្នកប្រើប្រាស់នឹងទទួលបានសារខ្លី ដែលបញ្ជាក់ពីស្ថានភាពលេខអាយម៉ីដោយស្វ័យប្រវត្តិពី IMEI KH។



លទ្ធផលស្ថានភាពលេខអាយម៉ីនឹងបង្ហាញ ១ក្នុងចំណោម ៤ប្រភេទដូចខាងក្រោម៖













## ៤.៤. ការពិនិត្យស្ថានភាពលេខអាយម៉ីតាមរយៈសេវាសារខ្លី (SMS)

អ្នកប្រើប្រាស់អាចពិនិត្យស្ថានភាពលេខអាយម៉ី នៃទូរសព្ទចល័តឬឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមតាមរយៈសេវាសារខ្លី (SMS) ដោយវាយ **CHK**<ដកឃ្លា><**លេខអាយម៉ី១៥ខ្ទង់**> រួចចុចបញ្ជូនទៅលេខ **1205**។ បន្ទាប់មកអ្នកប្រើប្រាស់នឹងទទួលបានសារខ្លី ដែលបញ្ជាក់ពីស្ថានភាពលេខអាយម៉ីដោយស្វ័យប្រវត្តិពី IMEI KH ។









លទ្ធផលស្ថានភាពលេខអាយម៉ីនឹងបង្ហាញ១ក្នុងចំណោម៤ប្រភេទដូចខាងក្រោម៖












# សៀវភៅមគ្គុទ្ទេសក៍

ស្ដីពី

មុខងារពិនិត្យស្ថានភាពលេខអាយម៉ី
នៃប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍
ទូរគមនាគមន៍ប្រើស៊ីម (ប្រព័ន្ធ EIRS)


ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ហៅចូល ឥតគិតថ្លៃ
1205
HOTLINE

MPTC.GOV.KH